YUNNAN DAILY PRESS GROUP
云南日报报业集团

ប្រទេសចិន-ខេត្តយូនណាន

ទស្សនាវដ្តីប្រចាំសប្តាហ៍

YUNNAN DAILY PRESS GROUP
english.yunnan.cn

ឆ្នាំទី 24 លេខ 7005 ថ្ងៃសុក្រ ទី 22 ខែមេសា ឆ្នាំ 2016

លោកស្យុងអាវចុងជើង ឯកប្រដាល់ខ្នាតទម្ងន់មធ្យម នៃខេត្តយូនណាននឹងចូលរួមការប្រកួតប្រដាល់ IBF

កីឬ្ធាករប្រដាល់ ស្យុង អាវចុង (ស្តាំ) កំពុងវាយទៅលើកីឬ្ធាករប្រដាល់ជប៉ុន ហ៊ីរ៉ូយ៉ាយ៉ាម៉ាម៉ូតូដើម្បីជ័យជម្នះដណ្តើមតំណែងជើងឯករបស់ស្តាប់ចំន WBC នៅក្នុងប្រភេទទម្ងន់មធ្យមកាលពីថ្ងៃទី ២២ ខែកុម្ភៈឆ្នាំ២០១៥ (រូបថតដោយ Lin Yiguang)

ដោយ : ឡូវ យាង

យោងតាមរបាយការណ៍ថ្មីៗនេះ លោកស្យុង អាវចុង ជើងឯកប្រដាល់ខ្នាតទម្ងន់មធ្យមនៃខេត្តយូនណាននឹងចូលរួមការប្រកួតប្រដាល់វគ្គជម្រុះថ្នាក់ទម្ងន់១០៥ផោន ដែលរៀបចំដោយ IBF ។ ប្រសិនបើលោកបានឈ្នះនិងទទួលបានសិទ្ធិប្រកួត ដើម្បីដណ្តើមខ្សែក្រវ៉ាត់មាសម្ចាស់ជើងឯកពិភពលោក ហើយលោកនឹងក្លាយជាមនុស្សទីមួយនៅប្រទេសចិន ដែលធ្លាប់ប្រកួតខ្សែក្រវ៉ាត់មាសម្ចាស់ជើងឯកពិភពលោកទាំងបីដែលរៀបចំដោយសមាគមកីឬ្ធាប្រដាល់ពិភពលោកធំទាំងបី ។

សមាគម IBF បានជ្រើសរើសកន្លែងកិច្ចប្រជុំប្រចាំឆ្នាំនៅទីក្រុងប៉េកាំង ។ ពេលនោះក្រៅពីឈ្នួញកណ្តាលអ្នកប្រដាល់ល្បីឈ្មោះប្រចាំទ្វីប អ្នកផ្សព្វផ្សាយកីឬ្ធាប្រដាល់កីឬ្ធាករ និងម្ចាស់ជើងឯកប្រដាល់នានានឹងចូលរួមកិច្ចប្រជុំប្រចាំឆ្នាំនេះ ហើយនឹងបង្កើតការប្រកួតប្រដាល់ដ៏មានទ្រង់ទ្រាយធំមួយនាថ្ងៃទី២៥ ខែឧសភា នៅទីក្រុងប៉េកាំង ។ ក្រៅពីការប្រកួតរបស់លោកស្យុងអាវចុងនោះនៅមានការប្រកួតមួយដែលលោកអាថៃឫលុនឡុង នៃប្រទេសថៃនឹងទទួលការណាត់ប្រដាល់ ពីលោកកាស៊ីមេល្ល នៃប្រទេសហ្វីលីពីនដើម្បីការពារម្ចាស់ជើងឯករបស់ខ្លួនលើកទី៦។

លោកស្យុង អាវចុង គឺជាមនុស្សស្រុកម៉ាក្វាន នៃខេត្តយូនណានដែលមានកម្ពស់ ១,៥៥ម៉ែត្រ គឺជាកីឬ្ធាករចិនតែម្នាក់គត់ ដែលធ្លាប់បានខ្សែក្រវ៉ាត់មាសទាំង៤នៃសមាគមកីឬ្ធាប្រដាល់ពិភពលោកធំទាំង៤ ។ លោកត្រូវគេដាក់ឈ្មោះថា ជើងឯកប្រដាល់ខ្នាតទម្ងន់មធ្យម ។ ក្នុងការប្រកួតប្រដាល់វគ្គជម្រុះថ្នាក់ទម្ងន់១០៥ផោនលើកនេះ លោកនឹងប្រកួតជាមួយនឹងលោកគីមេនីស មកពីប្រទេសកូឡុំប៊ី ។ កំណត់ត្រារបស់លោកគីមេនីស ដែលមានអាយុ៣២ឆ្នាំនោះ គឺការប្រកួត២២លើក ១៦ឈ្នះ ៥ចាញ់ មួយស្មើ ហើយបានវាយឱ្យសន្ទប់៧លើក ។ ប៉ុន្តែលោកគីមេនីសមិនដែលបានរង្វាន់ជើងឯកនៅទ្វីបណានៅឡើយទេ ។

អ្នកនាងអាយ ចុងជា កីឬ្ធាការិនីប្រដាល់នៅខេត្តយូនណានក៏នឹងចូលរួមការប្រកួតប្រដាល់មួយដែរ ។ ដូចនឹងលោកស្យុង អាវចុង ដែរ ប្រសិនបើអ្នកនាងបានឈ្នះនិងទទួលបានសិទ្ធិប្រកួតដើម្បីខ្សែក្រវ៉ាត់មាសម្ចាស់ជើងឯកពិភពលោក ។ សមាគម IBF សង្ឃឹមថានៅក្នុងការប្រកួតនេះនឹងកើតជើងឯកពិភពលោកស្ត្រីទីមួយនៅប្រទេសចិន។

លីចាំងត្រូវគេជ្រើសរើសក្នុងបញ្ជីជា "គោលដៅទេសចរណ៍ល្អបំផុតចំនួន១០នៅប្រទេសចិន"

បច្ចុប្បន្ននេះវេទិកាទេសចរណ៍ធំជាងគេនៅលើពិភពលោក Trip Advisor បានប្រកាសយ៉ាងឱឡារិកនូវបញ្ជី "ការជ្រើសរើសពីអ្នក ទេសចរឆ្នាំ ២០១៦ គោលដៅទេសចរណ៍ល្អ បំផុត ទូទាំងសកលលោក" ដោយទីក្រុងលីចាំង ត្រូវគេ ជ្រើសរើសនៅក្នុងបញ្ជី "គោលដៅទេសចរណ៍ល្អបំផុតចំនួន ១០នៅ ប្រទេសចិន" ជាលើកទីពីរ ។

បញ្ជី "ការជ្រើសរើសពីអ្នកទេសចរណ៍ឆ្នាំ២០១៦គោលដៅ ទេសចរណ៍ល្អបំផុតទូទាំងសកលលោក" គឺជ្រើសរើសដោយអ្នកទេសចរវាប់ពាន់រាប់ម៉ឺននាក់នៅទូទាំងពិភពលោកដោយផ្អែកលើការវាយតម្លៃចំពោះសណ្ឋាគារភោជនីយដ្ឋាន និង កន្លែងទេសចរណ៍នៅតាមតំបន់គោលដៅទេសចរណ៍នានា ដែលបានបង្ហាញយ៉ាងច្បាស់លាស់នូវកម្រិតនៃការទទួលចំណូលចិត្តពីអ្នកទេសចរទូទាំងពិភពលោក ។

នេះគឺជារូបភាពម្ចាស់ហាងលក់ឧបករណ៍តន្ត្រីកំពុងវាយស្គរជាមួយនឹងមិត្តភ័ក្ត្ររបស់នាងនៅក្នុងទីក្រុងបុរាណ Lijiang (រូបថតដោយ LiQiuming)

ទំនប់វារីអគ្គិសនីជីង ហុង របស់ចិនជួយសម្រាលភាពរាំងស្ងួតនៅបណ្តាប្រទេសនាតំបន់ទន្លេមេគង្គ

ចាប់ពីតាំងពីថ្ងៃទី១៥ ខែមីនា វារីអគ្គិសនីជីងហុងប្រទេសចិនបានបើកទ្វារទឹកដើម្បីបន្ថែមលំហូរទឹកដោយអនុវត្តន៍តាមបទបញ្ជាពីថ្នាក់ខាងលើ ដើម្បីបន្ធូរបន្ថយភាពរាំងស្ងួតនៃប្រទេសនៅតំបន់ទន្លេមេគង្គដូចជាប្រទេសឡាវ ភូមា ថៃ កម្ពុជានិងវៀតណាមជាដើម។

យោងតាមរបាយការណ៍នៃ "កាសែត ឌឹណេសិន"ប្រទេសថៃបានឱ្យដឹងថា មន្ត្រីនៃប្រទេសថៃម្នាក់បានថ្លែងថា ការបង្ហូរទឹកលើកនេះបានបង្ហាញថាការគ្រប់គ្រងធនធានទឹកឆ្លងដែននៃប្រទេសចិនមានភាពកាន់តែថ្នាហើយ ។ មុននឹងការបើកទ្វារបង្ហូរទឹករដ្ឋាភិបាលចិនបានសរសេរសំបុត្រឱ្យប្រទេសនានាដែលជាសមាជិកនៃគណៈកម្មការទន្លេមេគង្គដើម្បីជម្រាបផែនការបង្ហូរទឹក ។ ទន្ទឹមនឹងនេះ ប្រទេសចិនក៏ចាត់តាំងអ្នកការទូតចិនជម្រាបរដ្ឋាភិបាលប្រទេសនានា ។ លោកនាវឡា ឬ លោកវេនភីងវ៉ាដុម (Nuanla-or Wongpinitwarodom) នាយកនៃការិយាល័យគ្រប់គ្រងធនធានទឹកមេគង្គបានថ្លែងថា រដ្ឋាភិបាលប្រទេសចិនបានបង្ហាញថាប្រទេសចិនមានបំណងបង្កើនកិច្ចសហការឱ្យកាន់តែជិតស្និទ្ធជាមួយនឹងប្រទេសនានាផ្សេងទៀតនៅតំបន់ទន្លេមេគង្គ ដើម្បីដោះស្រាយបញ្ហានានាដែល មានការពាក់ព័ន្ធជាមួយគ្នា ។

តាមរបាយការណ៍នៃកាសែតនោះបានឱ្យដឹងថា ចាប់ពីថ្ងៃទី១៥ ខែមីនា ទន្លេឡានឆាងចាំងបានចាប់ផ្តើមបង្ហូរទឹកឆ្ពោះទៅទន្លេផ្នែកខាងក្រោមដោយមានទ្រង់ទ្រាយដល់២.០០០ម៉ែត្រត្រីគុណ/មួយវិនាទី ។ នៅតំបន់ឈ្យាងសែននៃខេត្តឈ្យាងរ៉ៃប្រទេសថៃដែលមានចម្ងាយ៣២៥គីឡូម៉ែត្រពីវារីអគ្គិសនីជីងហុងប្រទេសចិនជម្រៅទឹកទន្លេបានឡើងដល់៣,២៩ម៉ែត្រ យ៉ាងឆាប់រហ័សពីជម្រៅតែ២,៣-២,៥ម៉ែត្រ ការកើនឡើងនេះមានផលប្រយោជន៍ដល់នាវាចរណ៍នៃប្រទេសចិន ឡាវនិងថៃ ។

យោងតាមរបាយការណ៍ព័ត៌មានមួយប្រចាំថ្ងៃពីប្រទេសវៀតណាមនាថ្ងៃទី២ខែមេសាថា ទឹកដែលត្រូវបង្ហូរបន្ថែមពីប្រទេសចិនបានហូរដល់ខេត្តនានានៅជិតទន្លេមេគង្គ ។ នាភាគខាងលិចវៀតណាមបណ្តាអ្នកស្រែបានចាប់ផ្តើមសាបព្រោះស្រូវប្រាំងហើយ ។ លោកលីវ៉ានលីន(LêVán Lam) អ្នកស្រែម្នាក់នៅតំបន់ស្បៃនហុងខេត្តថុងថាប្រទេសវៀតណាមបានប្រាប់អ្នកកាសែតថា"ខ្ញុំបានចាប់ផ្តើមបង្កបង្កើនផលទំហំ១៥ហិកតា ពីរអាទិត្យមុនខ្ញុំនៅព្រួយណាស់ដោយសារនៅក្នុងប្រឡាយទឹកគឺគ្មានទឹកសោះឡើយ ប៉ុន្តែពេលបីថ្ងៃមុនទឹកក្នុងប្រឡាយបានកើន៣០សង់ទីម៉ែត្រឡើង មនុស្សទីនេះសុទ្ធតែរីករាយណាស់"។

លោកហឺ ជីនយូ នាយកនៃនាយកដ្ឋានវារីសាស្ត្រខេត្តស្ជ្ជ្ចាំងប្រទេសវៀតណាមបានថ្លែងថា "ទឹកដែលត្រូវបង្ហូរបន្ថែមមកនោះបានធ្វើឱ្យទំហំស្រូវស្រែដែលរងផលប៉ះពាល់នៅស្រុកនានាបានចុះដល់ក្រោម៣០ភាគរយ ហើយបានសង្គ្រោះស្រូវដែលកំពុងធើមដល់២.០០០ហិកតា"។

អ្នកនាងឆុនស្យៀតារាដើមកំណើតនៅទីក្រុងគុនមីញ ទទួលរង្វាន់ភាពយន្ត "រូបភាពមាស" នៅទីក្រុងហុងកុង

ដោយ : ម៉ា ជុនយ៉ាន់

នាងឆុនស្យៀតារាភាពយន្តដើមកំណើតគុណមិញ្ញចិត្តរួបជាមួយនឹង GuoFucheng ក្រោយទទួលពានរង្វាន់តារាសម្តែងល្អបំផុត (រូបថតដោយ Ma Junyan)

កាលពីពេលថ្មីៗនេះនាពិធីទទួលរង្វាន់ភាពយន្ត "រូបភាពមាស" នៅទីក្រុងហុងកុងភាពយន្តរឿង "ស្វែងរកផ្កាផ្នែព្រួនក្នុងហិម:" បានទទួលរង្វាន់ដល់ទៅចំនួន៧ ព្រមទាំងមានតារាសម្តែងប្រុសល្អបំផុត តារាសម្តែងស្រីល្អបំផុត តារាសម្តែងរងប្រុសល្អបំផុត និងតារាសម្តែងរងស្រីល្អបំផុត ។

នៅក្នុងមហោស្រពភាពយន្តលើកនេះ អ្នកនាងឆុនស្យៀ តារាដែលមានដើមកំណើតនៅទីក្រុងគុនមីញ បានទទួលតំណែងជាតារាសម្តែងស្រីល្អបំផុត ដោយបានក្លាយជាប្រធានបទក្តៅបំផុតនៅប្រទេសចិន ។ តារាពីគុនមីញដែលមានអាយុតែ២៣ឆ្នាំ និងបានសម្តែងខ្សែភាពយន្តទើបតែលើកទីមួយក៏ត្រូវគេជ្រើសរើសជាមហាក្សត្រិយភាពយន្តនៃរង្វាន់ភាពយន្ត "រូបភាពមាស" នៅទីក្រុងហុងកុង ។

អ្នកនាងឆុនស្យៀធ្លាប់ជាគំរូរូបភាពម្នាក់ ។ ឆ្នាំ២០១៣ នាងបានចូលរួមថតភាពយន្តភាគរឿង "ចិត្តខ្ញុំត្រចះត្រចង់" ។ ឆ្នាំ២០១៤ នាងបានចូលរួមថតភាពយន្តភាគ "ប្តីខ្ញុំជាបណ្ឌិត" នៅឆ្នាំដដែលគ្នានោះនាងបានសម្តែងក្នុងខ្សែភាពយន្តរឿង "ស្វែងរកផ្កាផ្នែព្រួនក្នុងហិម:"ហើយសម្តែងជាតួអង្គស្ត្រីទីមួយ។

នៅពិធីអបអរសាទរនៃភាពយន្ត "ស្វែងរកផ្កាផ្នែព្រួនក្នុងហិម:" អ្នកនាងឆុនស្យៀ បានសម្តែងថា នាងមិនស្មានថា នាងនឹងបានរង្វាន់នេះដែរ ។ នៅពេលទទួលរង្វាន់ អ្នកនាងមិនភ្លេចសម្តែងអំណរគុណចំពោះនាយកប្រចាំភាពយន្តនានា និងបុគ្គលិកម្នាក់ៗ ។ ក្រៅពីនេះនាងក៏បានបង្ហាញថា នាងមានសង្ឃឹមរហើយ គឺប្រុសម្នាក់ក្រៅវិស័យខ្សែភាពយន្ត ។

តាមពិតលើកនេះគឺលើកទី២ហើយ ដែលនាងបានទទួលរង្វាន់មហាក្សត្រិយភាពយន្ត ដោយពីមុននេះតាមរយៈភាពយន្តរឿង "ស្វែងរកផ្កាផ្នែព្រួនក្នុងហិម:" ដដែលអ្នកនាងបានទទួលរង្វាន់តារាសម្តែងស្រីល្អបំផុតនៅក្នុងមហោស្រពភាពយន្តអស្ចារ្យអន្តរជាតិនៃទីក្រុងហ្ជីឆុន ប្រទេសកូរ៉េខាងត្បូង (The PuchonInternatioal Fantastic Film Festiva) ម្តងដែរ ។

កិច្ចសហប្រតិបត្តិការសុខាភិបាលនៅតាមព្រំដែនប្រទេសចិន និងឡាវមានប្រសិទ្ធភាពគួរឱ្យកត់សម្គាល់

ដោយៈដែ ចិនហ្ស

ពេលបច្ចុប្បន្ននេះសិស្សប្រទេសឡាវ៣៤នាក់ដែលបានចូលរួម"ការបណ្តុះបណ្តាលខាងជំនាញគិលានុបដ្ឋាកនៅមន្ទីរពេទ្យរបស់រដ្ឋស៊ីស្វាងប៉ាន់ណាប្រទេសចិនជាមួយនឹងខេត្តទាំង៥ភាគខាងជើងឡាវ"បានបញ្ចប់ការសិក្សាទាំងអស់ និងជាប់ការប្រឡងទាំងឡាយ ហើយបានទទួលវិញ្ញាបនបត្រជំនាញគិលានុបដ្ឋាកដែលចែកដោយប្រទេសចិន។

បន្ទាប់ពីបានអនុវត្តន៍កម្មវិធី "កិច្ចសហប្រតិបត្តិការខាងសុខាភិបាលរវាងគណៈកម្មាធិការសុខភាពជាតិចិន និងខេត្តទាំង៥ភាគខាងជើងឡាវ" នោះរៀងមក មន្ទីរពេទ្យប្រជាជននៃរដ្ឋស៊ីស្វាងប៉ាន់ណាខេត្តយូណានបានពង្រឹងកិច្ចសហប្រតិបត្តិការខាងសុខាភិបាលដោយមិនដែលឈប់ឈរ ហើយបានស្វែងរកយន្តការថ្មីនៃកិច្ចសហការខាងសុខាភិបាលនៅតាមព្រំដែន ដោយបានទទួលផ្លែផ្កាគ្រាន់បើហើយ ។

តាមដំណឹងថា កម្មវិធី"កិច្ចសហប្រតិបត្តិការខាងសុខាភិបាលរវាងគណៈកម្មាធិការសុខភាពជាតិចិន និងខេត្តទាំង៥ភាគខាងជើងឡាវ" នោះបានព្រមឱ្យមានការផ្លាស់ប្តូរបុគ្គលិកការបណ្តុះបណ្តាលខាងសុខាភិបាល វេទិកានាយកមន្ទីរពេទ្យ និងការកសាងរួមគ្នានូវសេវាកម្មសុខាភិបាលជាដើម។ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ "សហគមន៍សុខាភិបាលរវាងប្រទេសចិននិងខេត្តទាំង៥ ភាគខាងជើងប្រទេសឡាវ"ដែលរួមមានខេត្តហ្ជង ព្រះបាងខេត្តអ្ជុមក្សេ ខេត្តលួងណាមថា ខេត្តភូចរនិងខេត្តហ្ជងសាលីប្រទេសឡាវនោះ ត្រូវបានបង្កើតឡើង ។ ផ្នែកលើវេទិកានេះ មន្ទីរពេទ្យប្រជាជននៃសកលវិទ្យាល័យប៉េកាំងអាចយកមន្ទីរពេទ្យប្រជាជនរដ្ឋស៊ីស្វាងប៉ាន់ណាជាស្ពានដើម្បីណែនាំនិងជួយដល់មន្ទីរពេទ្យនៃខេត្តទាំង៥ភាគខាងជើងប្រទេសឡាវនៅក្នុងការពិភាក្សាអំពីជំងឺដែលមិនងាយព្យាបាលបានការពិភាក្សា ព្យាបាលពីចម្ងាយ(Teleconsultation) ការសិក្សាជំនាញវេជ្ជសាស្ត្រជាដើម ។

ក្នុងរយៈពេលជាង១ឆ្នាំនៃការអនុវត្តន៍នៃកម្មវិធីនេះ ភាគីទាំងចិននិងឡាវបានផ្លាស់ប្តូរបុគ្គលិកជាង១៣៩នាក់ ។ មន្ទីរពេទ្យប្រជាជនរដ្ឋស៊ីស្វាងប៉ាន់ណាខេត្តយូណានបានចាត់ចែងក្រុមគ្រូពេទ្យ២ក្រុម ដែលរួមមានគ្រូពេទ្យ១២រូប ទៅធ្វើការនៅមន្ទីរពេទ្យខេត្តលួងណានថា និងរៀនភាសាឡាវនៅប្រទេសឡាវ ។